**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Nov-2011, 08:50
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងសវនាការនៅដំណាក់កាលដំបូង**

**(ថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គឹមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**<u>ផ្ញើជូន៖</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ជា លាង

Andrew T. CAYLEY

យ៉ែត ចរិយា

William SMITH

យុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Herve DIAKIESE
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Silke STUDZINSKY
Philippine SUTZ

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

ស សូវ៉ាន

Jacques VERGES

# I. ប្រវត្តិនីតិវិធី និងបរិបទ

១. នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ និងសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ អំពីគោលបំណងរបស់ខ្លួន ក្នុងការចាប់ផ្តើមសវនាការលើអង្គសេចក្តី ដោយពិចារណាទៅលើអង្គសេចក្តីចំនួនបួនផ្នែក ក្នុងសវនាការនៅដំណាក់កាលដំបូង ពោលគឺ "(១) រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ (២) តួនាទីរបស់ជនជាប់ចោទនីមួយៗ នៅក្នុងអំឡុងពេលមុនការបង្កើតកម្ពុជាប្រជាធិបតេយ្យ ដោយរួមទាំងពេលវេលានៃការចាត់តាំងតួនាទីទាំងនេះផងដែរ (៣) តួនាទីរបស់ជនជាប់ចោទនីមួយៗ នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវដែលបានចាត់តាំងឱ្យពួកគាត់ វិសាលភាពនៃការទទួលខុសត្រូវទាំងនោះ វិសាលភាពនៃអំណាចរបស់ពួកគាត់ និងខ្សែរយៈទំនាក់ទំនងនៅក្នុងអំឡុងពេល ដែលជាយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក និង (៤) គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ទាក់ទងទៅនឹងបញ្ហានានាដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ"[១]។

២. នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញ "សេចក្តីជូនដំណឹងជាមុនអំពីកាលបរិច្ឆេទសម្រាប់ដាក់បញ្ជីឯកសារ ឬវត្ថុតាងបន្ថែម"[២] ពាក់ព័ន្ធនឹងបញ្ហានៅក្នុងផ្នែកទាំងបួនខាងលើនេះ។

៣. ហេតុដូច្នេះ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បញ្ជីឯកសារ និងវត្ថុតាង ដែលបានកែប្រែ ពាក់ព័ន្ធទៅនឹងផ្នែកទាំងបួននៃសវនាការនៅដំណាក់កាលដំបូងនេះ[៣]។ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ឧបសម្ព័ន្ធដូចខាងក្រោម៖

- *ឧបសម្ព័ន្ធក(i) ដែលបានកែប្រែ*[៤] រៀបរាប់អំពីឯកសារជាក់លាក់នានា ដែលមាននៅក្នុងសំណុំរឿងរួចហើយ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងសវនាការនៅដំណាក់កាលដំបូង។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា

---

[១] ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រទី ៥២។

[២] ឯកសារ E103.1.1; Trial Chamber's proposed modification of deadlines in relation to three recent Prosecution findings, advance notices of deadline for supplementary document/exhibit lists (for first phase of trial).

[៣] ឯកសារ E109/2 បញ្ជីឯកសារ/វត្ថុតាងដែលត្រូវបានកែប្រែដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ចំនុចផ្នែកច្បាប់ចំនួន ៤ ដំបូង។

[៤] ឯកសារ E109/2.1, ឧសម្ព័ន្ធ ក (i)និង (ii) ដែលត្រូវបានកែប្រែ ( ឯកសារដែលមាននៅក្នុងសំណុំរឿងស្រាប់ដាក់ជូនទៅអង្គជំនុំជម្រះ)

ឯកសារទាំងនេះមានភាពពាក់ព័ន្ធទៅនឹងផ្នែកទីមួយ និងផ្នែកទីបួន នៃសវនាការនៅដំណាក់កាលដំបូង។

- *ឧបសម្ព័ន្ធ ៧ក(ii)ដែលបានកែប្រែ* [៥] គឺជាបញ្ជីសារពើភ័ណ្ឌនៃរាល់ឯកសារគាំទ្រទាំងអស់ ដែលបានដកស្រង់ចេញពីផ្នែកនានានៃដីកាដំណោះស្រាយ និងដែលពាក់ព័ន្ធទៅនឹងផ្នែកទាំងបួននៃសវនាការនៅដំណាក់កាលដំបូង។
- *ឧបសម្ព័ន្ធ ៧ក(iii)ដែលបានកែប្រែ* [៦] រួមបញ្ចូលនូវរាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលអាចទទួលយកបានទាំងអស់ ដោយពិចារណាឃើញថា "ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជារួម មានផ្ទុកនូវភស្តុតាងសំខាន់ៗ ស្ដីពីរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា"។
- *ឧបសម្ព័ន្ធ ៧ខដែលបានកែប្រែ* [៧] គឺជាបញ្ជីឯកសារថ្មីៗ ដែលពាក់ព័ន្ធទៅនឹងផ្នែកទាំងបួននៃសវនាការនៅដំណាក់កាលដំបូង។
- *ឧបសម្ព័ន្ធ ៧គដែលបានកែប្រែ* [៨] គឺជាបញ្ជីវត្ថុតាងនានា ពាក់ព័ន្ធទៅនឹងផ្នែកទាំងបួននៃសវនាការនៅដំណាក់កាលដំបូង ដែលមាននៅក្នុងសំណុំរឿងរួចហើយ។

៤. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង"[៩] ដែលបំបែកកិច្ចដំណើរការនីតិវិធី ឱ្យទៅជាសវនាការផ្សេងៗគ្នាមួយចំនួន ហើយតាមរយៈដីកាសម្រេចនេះ អង្គជំនុំជម្រះបញ្ជាក់ថា សវនាការនៅដំណាក់កាលដំបូង នឹងត្រូវធ្វើឡើងពាក់ព័ន្ធទៅនឹង "*(ក) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និង (ខ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផល*

---

[៥] ដូចលេខយោងជើងទំព័រខាងលើ។

[៦] ឯកសារ E109/2.2, ឧសម្ព័ន្ធ ៧ក (iii) ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

[៧] ឯកសារ E109/2.3, ឧសម្ព័ន្ធ ៧ ខ (ឯកសារថ្មីដែលស្នើដាក់បញ្ចូលសម្រាប់សវនាការដំបូងទាក់ទងនឹងចំនុចផ្លូវច្បាប់ទាំង៤ និង ឧសម្ព័ន្ធ គ (បញ្ជីភស្តុតាងដែលទាក់ទងចំនុចផ្លូវច្បាប់ទាំងបួនដំបូង)។

[៨] ដូចលេខយោងជើងទំព័រខាងលើ។

[៩] ឯកសារ E124 ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

*សាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ត្រង់ផ្នែកទាំងឡាយណាដែលអង្គហេតុទាំងនេះ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)*"[១០]។

៥. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះ បានចេញដីកាកំណត់កាលបរិច្ឆេទ[១១] នៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២។ ដីកានេះបានកំណត់ការចាប់ផ្ដើម និងរយៈពេលនៃផ្នែកដំបូងនៃសវនាការស្ដីពីការដាក់ភស្តុតាងនៅក្នុងសំណុំរឿង ០០២ ចាប់ពីថ្ងៃ ច័ន្ទ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ រហូតដល់ថ្ងៃ សុក្រ ទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១។

៦. នៅក្នុងអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះ បានបង្គាប់ឱ្យភាគីនានា បញ្ជាក់ឱ្យបានមុនថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ "*ថាតើឯកសារ និងវត្ថុតាងណាមួយ នៅក្នុងបញ្ជីដំបូងរបស់ខ្លួន ដែលខ្លួនមានបំណងចង់ឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយក ទាក់ទងទៅនឹងឈ្មោះសាក្សី និងអ្នកជំនាញ ដែលអាចនឹងត្រូវបានកោះហៅ ក្នុងអំឡុងពេលសវនាការរយៈពេលបីសប្ដាហ៍ដំបូង*"[១២]។

## II. សំណើសុំធ្វើការកែតម្រូវទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E131/1

៧. អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E131/1 ធ្វើការពណ៌នាឯកសារ ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើឡើងថាជា "*ឯកសារទាំងអស់ដែលដីកាដំណោះស្រាយបានយកមកធ្វើជាឯកសារយោងនៅត្រង់ជើងទំព័រនៃដីកានេះ និងឯកសារចំនួន ២៤ ទៀតនៅក្នុងសំណុំរឿង (ឯកសារ E109/2)*"[១៣]។

៨. ការពណ៌នានេះ មិនមានលក្ខណៈពេញលេញនោះទេ។ ដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៣ ខាងលើ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានដាក់ *ឧបសម្ព័ន្ធ ៧ក(iii)ដែលបានកែប្រែ* ដែលរួមបញ្ចូលនូវគ្រប់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចទទួលយកបានទាំងអស់ ដោយពិចារណា

---

[១០] សូមមើលលេខយោងជើងទំព័រ លេខ២ នៅកថាខណ្ឌ ២ ខាងលើ។

[១១] ឯកសារ E131 ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១។

[១២] ឯកសារ E131/1។

[១៣] ឯកសារ E131/3។

ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជារួម មានផ្ទុកនូវភស្តុតាងសំខាន់ៗ ស្តីពីវចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

៩. ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីកែប្រែមួយ ដោយរៀបរាប់នូវរាល់ឯកសារទាំងអស់ ដែលបានដាក់សម្រាប់ផ្នែកទាំងបួននៃសវនាការដំណាក់កាលដំបូងនេះ។

## III. **បញ្ជីឯកសារដែលបានកែប្រែ ចេញពីឯកសារ E109 សម្រាប់សវនាការនៅដំណាក់កាលដំបូង**

១០. ឧបសម្ព័ន្ធ "ខ"[១៤] នៃអនុស្សរណៈខាងលើនេះ ផ្តល់ឱ្យជាព័ត៌មានស្តីអំពីវគ្គដំបូងនៃសវនាការ (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) ពាក់ព័ន្ធទៅនឹងលំដាប់លំដោយនៃការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធី និងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលអាចនឹងត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។

១១. ទោះបីជាអង្គជំនុំជម្រះបញ្ជាក់ថា ខ្លួននឹងចាប់ផ្តើមសវនាការ ដោយលើកយកផ្នែកដំបូង ពោលគឺ "វចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ" មកដោះស្រាយមុនក៏ដោយ អង្គជំនុំជម្រះក៏បញ្ជាក់ផងដែរថា "*ទោះបីអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យសាកសួរដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីទាំងនេះទាក់ទិននឹងគោលនយោបាយ និងការអនុវត្តទូទៅពាក់ព័ន្ធនឹងផ្នែកផ្សេងទៀតនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏ភាគីត្រូវផ្តោតសំណួរជាក់លាក់របស់ខ្លួនដែលនឹងត្រូវសួរដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីម្នាក់ៗ ចំពោះអង្គហេតុដែលពាក់ព័ន្ធ នឹងប្រធានបទនៃសវនាការដំណាក់កាលដំបូងប៉ុណ្ណោះ។ ក្នុងករណីចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចកោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាថ្មីទៀត ដើម្បីពិនិត្យពិចារណាលើអង្គហេតុលម្អិត នៅក្នុងសវនាការលើកក្រោយៗទៀត*"[15]។

១២. ដោយបានពិចារណាទៅលើការលើកឡើងខាងលើ ដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយកនូវរាល់ឧបសម្ព័ន្ធទាំងអស់នៃឯកសារ E109/2 ដែលមានដូចជា៖

---

[១៤] ឯកសារ E131/1.2 ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ដែលនឹងត្រូវកោះហៅឱ្យចូលរួមក្នុងការជំនុំជម្រះនៅដំណាក់កាលដំបូង នៃសំណុំរឿង ០០២ (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)។

[១៥] E131/1.2, ឧបសម្ព័ន្ធសម្ងាត់ ខ ៖ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ដែលត្រូវកោះហៅឱ្យចូលរួមក្នុងការជំនុំជម្រះនៅដំណាក់កាលដំបូងនៃសំណុំរឿង ០០២។

- **E109/2.1** ឯកសារភ្ជាប់ទី១ ឧសម្ព័ន្ធ ៧ក ដែលត្រូវបានកែប្រែ- ឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង ស្នើដាក់ចូលសម្រាប់សវនាការ
- **E109/2.2** ឯកសារភ្ជាប់ទី២ ៖ ឧសម្ព័ន្ធ ៧ក (iii) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- **E109/2.3** ឯកសារភ្ជាប់ទី៣ ឧសម្ព័ន្ធ ៧ខ- ឯកសារថ្មីដែលស្នើដាក់ចូលសម្រាប់ជំនុំជម្រះទាក់ទងនឹងចំនុចផ្លូវច្បាប់ទាំង ៥។

សូមដាក់ជូនដោយសេចក្តីគោរព

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ធ្វើនៅ** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ | **ពេជ អង្គ**<br>**សហមេធាវីនាំមុខជាតិ** | ភ្នំពេញ | |
| | **Elisabeth SIMONNEAU FORT**<br>**សហមេធាវីនាំមុខអន្តរជាតិ** | ភ្នំពេញ | |